អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ភូមិសំអាត



សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

អ្នកនិពន្ធ៖ លី ហាន់ណាហ្វី

រូបភាពដោយ៖ សែម រ៉ាស៊ីន



វ៉ាយុទ្ធជាក្មេងរស់នៅទីជនបទ។

គាត់ជាកុមារម្នាក់ដែលមានសណ្ដាប់ធ្នាប់និងអនាម័យល្អ

ហើយគាត់តែងតែជួយការងារផ្ទះម្ដាយគាត់ជារៀងរាល់ថ្ងៃ។





រ៉ាយុទ្ធតែងតែដើរទៅសាលារៀនជារៀងរាល់ព្រឹក។

នៅតាមផ្លូវរ៉ាយុទ្ធបានជួបនឹងមិត្តរួមថ្នាក់ម្នាក់ឈ្មោះ សំណាង។



សំណាងបានបោះសំរាមចោលតាមផ្លូវពេលដែលគាត់កំពុង
ធ្វើដំណើរទៅសាលារៀនជាមួយឪពុកគាត់។




រ៉ាយុទ្ធបានឃើញបែបហ្នឹង ហើយក៏រើសសំរាមនោះ ដើម្បីបោះចោលនៅសាលារៀន ព្រោះតាមផ្លូវគ្មានធុងសំរាមទេ។ ជារៀងរាល់ព្រឹក រ៉ាយុទ្ធតែងតែរើសសំរាមតាមដងផ្លូវបានយ៉ាងច្រើន ទម្រាំគាត់ដើរទៅដល់ថ្នាក់រៀន។ ដៃរបស់គាត់កាន់សុទ្ធតែសំរាម។



ពេលវ៉ាយុទ្ធទៅដល់សាលារៀន មិត្តរបស់គាត់តែងតែសើចចំអកឱ្យគាត់
ហើយហៅគាត់ថា ក្មេងសំរាម។
វ៉ាយុទ្ធមិនសប្បាយចិត្តហើយថែមទាំងយំទៀតផង។




ថ្ងៃមួយ អ្នកគ្រូបង្រៀនក្មេងៗទាំងអស់ពីមេរៀនមួយដែលនិយាយពីផលប៉ះពាល់របស់សំរាមនិងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។



អ្នកគ្រូបាននិយាយប្រាប់កុមារទាំងអស់គ្នាថា
ការចោលសំរាមតាមដងផ្លូវផ្តេសផ្តាសធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន
ខ្យល់មានជាតិពុល បំពុលទឹកនិងដីក្លានដីជាតិ។




អ្នកគ្រូសួរក្មេងៗ ‹‹តើកូនៗចូលចិត្តសំរាមដែរឬទេ? តើកូនៗចង់ឃើញសំរាមនៅពាសពេញដី ក្នុងទឹកដែរឬទេ?›› សំណាងបានឆ្លើយ ‹‹បាទ អ្នកគ្រូ! ខ្ញុំមិនចូលចិត្តទេ ហើយក៏មិនចង់ឃើញសំរាមមាននៅគ្រប់ទីកន្លែងដែរ››។ អ្នកគ្រូសួរបន្ត ‹‹នៅពេលដែលកូនៗបានឃើញសំរាមតាមដងផ្លូវ តើកូនៗគួរធ្វើដូចម្តេច?›› សំណាងបានឆ្លើយ ‹‹ពួកយើងត្រូវតែរើសវាចោលក្នុងធុងសំរាម››។



និយាយឃ្សួចសំណាងក៏បានមើលទៅមុខវ៉ាយុទ្ធហាក់បីដូចជាដឹងខ្លួនខុសថា
មិនគួរនិយាយបង្អាប់មិត្តបែបហ្នឹងនោះទេ។



ពេលចេញលេង សំណាងក៏បាននិយាយទៅកាន់វ៉ាយុទ ‹‹ វ៉ាយុទ្ធហ៊ា
ឱ្យខ្ញុំសុំទោសណាដែលនិយាយមិនល្អដាក់ឯង ››។



វ៉ាយុទ្ធក៏មិនបានខឹងនឹងសំណាងដែរ។

ពួកគេតែងតែលេងជាមួយគ្នាយ៉ាងសប្បាយរីករាយនៅសាលារៀន។



មិនយូរប៉ុន្មាន តាមផ្លូវទៅសាលារៀនមិនឃើញមានសំរាមដូចមុនទៀតទេ។
រ៉ាយុទ្ធសប្បាយចិត្តវិញហើយ។